ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# លិខិតជូនពរ

## សូមគោរពជូន

## សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន

**សម្តេចធម្មវិសុទ្ធវង្សា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសដ៏បវរសួស្តី សិរីមង្គលមហាប្រសើរ នៃពិធីចម្រើនជន្មាយុគម្រប់៨៤ឆ្នាំ ឈានចូល៨៥ឆ្នាំ របស់ **សម្តេចធម្មវិសុទ្ធវង្សា** នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅ ជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ មានកាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រពៃនេះ យើងខ្ញុំសូមអនុញ្ញាតសម្តែងនូវការកោតសរសើរដ៏ស្មោះ ចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចធម្មវិសុទ្ធវង្សា** ដែលជានិច្ចកាលតែងតែរួមដំណើរជម្រុញលើកទឹកចិត្ត និងគាំទ្រ **សម្តេចអគ្គមហាពញាចក្រី** នៅក្នុងបេសកកម្មដឹកនាំស្ថាប័ននីតិបញ្ញត្តិ ឱ្យបានល្អប្រសើរជូនប្រទេសជាតិមានសន្តិភាព និងស្ថិរភាព ក៏ដូចជារួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។ **សម្តេច** ជាឧត្តមភរិយា ជាមាតា និងជាជីដូន ជាជីដូនទួត ប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ និងជាគំរូដ៏ប្រពៃសម្រាប់ស្ត្រីគ្រប់រូបគោរពនិងដើរតាមមាគ៌ានេះ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិលើលោក ប្រសិទ្ធពរជ័យជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន និង សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ និងទទួលបានពុទ្ធពរដ៏មហាប្រសើរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចធម្មវិសុទ្ធវង្សា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ សុខា